# គណៈកម្មការទន្លេមេគង្គ

ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ ០១០០០ សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ទូរស័ព្ទលេខ ៨៥៦-២១ ២៦៣២៦៣   ទូរសារលេខ ៨៥៦-២១ ២៦៣២៦៤

អ៊ីម៉ែល: mrcs@mrcmekong.org  វិបសាយ: www.mrcmekong.org


## ព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ

## លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ចាប់ផ្តើមរើទៅកាន់ការិយាល័យទីពីររបស់ខ្លួននៅប្រទេសកម្ពុជា

***ទីតាំងការិយាល័យពីររបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅភ្នំពេញ និងវៀងច័ន្ទ ចាប់ផ្តើមនៅខែកក្កដានេះ***

*វៀងច័ន្ទ សាធារដ្ឋប្រជាមានិតឡាវ*

*៧ កក្កដា ២០១០*

គណៈកម្មការទន្លេមេគង្គ ចាប់ផ្តើមដំណើរការបែងចែកការិយាល័យលេខាធិការដ្ឋានរបស់ខ្លួន ជាពីរ គឺការិយាល័យលេខាធិការដ្ឋាននៅទីក្រុងវៀងច័ន្ទ និងការិយាល័យលេខាធិការដ្ឋាននៅទីក្រុងភ្នំពេញ ក្រោយពេលដែលប្រទេសទាំងពីរបានព្រមព្រៀងគ្នាកាលពីឆ្នាំ ២០០៩ ថានឹងដាក់ការិយាល័យលេខាធិការដ្ឋានជាអចិន្ត្រៃយ៍នៅក្នុងប្រទេសទាំងពីរ។

ការព្រមព្រៀងគ្នាកាលពីឆ្នាំ ១៩៩៦ បានចែងថានឹងរើទីតាំងលេខាធិការដ្ឋានរាល់ ៥ឆ្នាំម្តង។ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ដែលសព្វថ្ងៃមានបុគ្គលិកច្រើនជាង ១៥០ នាក់ ត្រូវដល់ពេលរើទៅទីក្រុងភ្នំពេញនៅឆ្នាំ ២០១០។

ក៏ប៉ុន្តែ នៅឆ្នាំ ២០០៩ ក្រោយពីមានការចរចារគ្នាជាច្រើនលើកមក រដ្ឋាភិបាលនៃប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គទាំងបួនដែលរួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម បានសំរេចធ្វើវិមជ្ឈការនៃការគ្រប់គ្រងគណៈកម្មការទន្លេមេគង្គ។

លោកជេរីមី ប៊ីតប្រធានលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និយាយថា “ប្រទេសទាំងបួន បានព្រមព្រៀងគ្នាថា បទពិសោធន៍នៃការផ្លាស់ប្តូរទីតាំងរាល់ពេល៥ឆ្នាំកន្លងមកតាមកិច្ចព្រមព្រៀងពីមុន បណ្តាលអោយមានការលំបាកផ្នែកភស្តុភារ។ ក្រៅពីត្រូវចំណាយលើការរើទីតាំង ការផ្លាស់ប្តូររាល់ប្រាំឆ្នាំម្តង

ក៏ប៉ះពាល់ដល់កម្មវិធីការងារ និងធនធានមនុស្ស ព្រមទាំងបង្ករការលំបាកដល់ការកំណត់ទិសដៅយុទ្ធសាស្ត្ររបស់អង្គការទៀតផង។”

លោកជេរីមី ប៊ីត និយាយថា “សេចក្តីសំរេចសើរើកិច្ចសម្របសម្រួលលែងផ្លាស់ប្តូរទីតាំងរាល់ប្រាំឆ្នាំម្តងនេះនឹងបង្កើនប្រសិទ្ធភាពការងារ និងនិរន្តរភាពរបស់អង្គការ ព្រមទាំងធ្វើអោយយើងអាចផ្តោតការយកចិត្តទុកដាក់បន្ថែមលើកាលានុវត្តភាពអភិវឌ្ឍន៍សំខាន់ៗ ហើយនិងការប្រឈមមុខដែលកើតមាននៅតាមអាងទន្លេមេគង្គ។”

ការិយាល័យលេខាធិការដ្ឋានអចិន្ត្រៃយ៍ទាំងពីរត្រូវបានបង្កើតនៅខែកក្កដានេះ។ ទីតាំងការិយាល័យមួយស្ថិតនៅទីក្រុងវៀងច័ន្ទ និងទីតាំងការិយាល័យមួយទៀតនៅទីក្រុងភ្នំពេញដែលស្ថិតនៅក្នុងអគារមជ្ឈមណ្ឌលកាត់បន្ថយ និងគ្រប់គ្រងគ្រោះទឹកជំនន់សព្វថ្ងៃ។

គណៈកម្មការទន្លេមេគង្គ និយាយថា ការិយាល័យប្រធានលេខាធិការដ្ឋាន ការិយាល័យប្រធានផ្នែកសេវាកម្មគាំទ្រ ព្រមទាំងការិយាល័យផ្នែកកម្មវិធីចំនួនពីរ នឹងបន្តតាំងនៅលេខាធិការដ្ឋាននាទីក្រុងវៀងច័ន្ទ។ រីឯផ្នែកកម្មវិធីពីរទៀត និងបុគ្គលិកតំណាងផ្នែកសេវាកម្មគាំទ្រ បានចាប់ផ្តើមរើទៅកាន់លេខាធិការដ្ឋាននៅទីក្រុងភ្នំពេញជាបណ្តើរៗ។ សកម្មភាពរើ នឹងបញ្ចប់នៅចុងឆ្នាំ ២០១០នេះ។

កម្មវិធីដែលត្រូវរើទៅកាន់លេខាធិការដ្ឋាននៅទីក្រុងភ្នំពេញ រួមមានកម្មវិធីធារាសាស្ត្រ និងកសិកម្ម គំរោងគ្រប់គ្រងគ្រោះរាំងស្ងួត កម្មវិធីជលផល និងកម្មវិធីនាវាចរ។ កម្មវិធីទាំងអស់នេះ នឹងរើទៅកាន់អគាររួមជាមួយកម្មវិធីកាត់បន្ថយ និងគ្រប់គ្រងគ្រោះមហន្តរាយដែលស្ថិតនៅទីក្រុងភ្នំពេញស្រាប់តាំងពីឆ្នាំ ២០០៩មក។ កម្មវិធីដែលបន្តនៅលេខាធិការដ្ឋានទីក្រុងវៀងច័ន្ទ មានភាពពាក់ព័ន្ធច្រើននឹងការធ្វើផែនការនៅទូទាំងអាងទន្លេមេគង្គទាំងមូល ដែលក្នុងនោះរួមមានកម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ គំរោងគ្រប់គ្រងធនធានទឹកចម្រុះនៅទន្លេមេគង្គ គំនិតផ្តួចផ្តើមអំពីការអភិវឌ្ឍវារីអគ្គិសនីដោយនិរន្តរភាព កម្មវិធីបរិស្ថាន ហើយនិងគំនិតផ្តួចផ្តើមអំពីអាកាសធាតុប្រែប្រួល និងការបន្សាំនឹងអាកាសធាតុប្រែប្រួល។

ប្រទេសសមាជិកទាំងបួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទន្លេមេគង្គ ១៩៩៥។ ជាមួយនឹងកិច្ចព្រមព្រៀងនេះ គណៈកម្មការទន្លេមេគង្គត្រូវបានបង្កើតឡើង។ មួយឆ្នាំក្រោយមក នៅឆ្នាំ ១៩៩៦ ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ បានព្រមព្រៀងថា ទីតាំងនៃលេខាធិការដ្ឋាននឹងត្រូវផ្លាស់ទៅមករវាងទីក្រុងភ្នំពេញ និងវៀងច័ន្ទរៀងរាល់ប្រាំឆ្នាំ។ ចាប់ពីឆ្នាំ ១៩៩៨ មក លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គមានទីតាំងនៅភ្នំពេញ ហើយបន្ទាប់មកត្រូវបានរើទៅទីក្រុងវៀងច័ន្ទតាំងពីឆ្នាំ ២០០៤ រហូតមកដល់សព្វថ្ងៃនេះ។

----------

**សំរាប់ព័ត៌មានបន្ថែម** សូមទាក់ទងលោក ដាមាន គាន ទីប្រឹក្សាផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈអ៊ីមែល damian@mrcmekong.org ទូរស័ព្ទលេខ (៨៥៦-២០) ៧៥២ ៧៥០០